អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ៥០/២៦ ចេញផ្សាយ ខែកុម្ភៈ ឆ្នាំ២០២៦

## សារៈសំខាន់នៃការគ្រប់គ្រងទ្រព្យសកម្ម




**ការគ្រប់គ្រងទ្រព្យសកម្ម** គឺជាប្រព័ន្ធដំណើរការមួយដ៏សំខាន់ក្នុងការអភិវឌ្ឍកិច្ចប្រតិបត្តិការ ការទិញ ការប្រើប្រាស់ ការថែទាំ និងការជម្រះទ្រព្យសកម្មរបស់ស្ថាប័ន ដែលមានដូចជា ទ្រព្យសម្បត្តិហិរញ្ញវត្ថុ អគារ ឬឧបករណ៍ ក្នុងការសម្រេចបាននូវគោលដៅរបស់ស្ថាប័ន ចំណាយសមរម្យ កាត់បន្ថយហានិភ័យ និងការប្រើប្រាស់បានយូរអង្វែង។ បន្ថែមពីនេះ ការគ្រប់គ្រងទ្រព្យសកម្មមានសារៈសំខាន់ណាស់សម្រាប់ស្ថាប័ន ព្រោះទ្រព្យសកម្ម គឺជាធនធានដ៏មានតម្លៃ ដែលស្ថាប័នត្រូវការដើម្បីគាំទ្រកិច្ចដំណើរការប្រចាំថ្ងៃ និងមុខងាររបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាពខ្ពស់។បើស្ថាប័នមានប្រព័ន្ធគ្រប់គ្រងទ្រព្យសកម្មបានល្អ នោះក៏អាចធានាបាននូវការសន្សំថ្លៃដើម ការធ្វើឲ្យដំណើរការល្អប្រសើរ ការបង្កើនអាយុកាលប្រើប្រាស់ទ្រព្យ-សកម្ម និងការប្រើប្រាស់ប្រកបដោយចីរភាព។ ការគ្រប់គ្រងទ្រព្យសម្បត្តិ មិនមែនត្រឹមតែផ្តល់អត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះទេ ថែមទាំងអាចជួយឲ្យស្ថាប័នតាម-ដាននូវទ្រព្យសម្បត្តិរបស់ខ្លួន អាចគ្រប់គ្រង និងដឹងពីគណនេយ្យទ្រព្យសកម្មទាំងអស់របស់ខ្លួនត្រង់ទីតាំងណាមួយ, ជួយធានាអត្រារំលោះទ្រព្យសកម្មបានត្រឹមត្រូវ, អាចកំណត់ និងគ្រប់គ្រងហានិភ័យបានល្អជាងមុន, អាចលុបទ្រព្យសកម្មដែលបាត់បង់ ឬទ្រព្យសកម្មដែលឈប់ដំណើរការ ឬមិនមានជាក់ស្តែងជារូបវន្តចេញពីបញ្ជីសារពើភ័ណ្ឌ ជួយសន្សំថវិកា និងធនធានរបស់ស្ថាប័ន។ បន្ថែមពីនេះ ប្រព័ន្ធគ្រប់គ្រងទ្រព្យសកម្មបានល្អ ក៏បានផ្តល់នូវសារៈសំខាន់ៗរួមមាន៖




- **ការសន្សំចំណាយ៖** តាមរយៈការគ្រប់គ្រងទ្រព្យសកម្មប្រកបដោយប្រសិទ្ធភាព និងការអនុវត្តយុទ្ធសាស្ត្រថែទាំប្រកបដោយប្រសិទ្ធភាព ស្ថាប័នអាចសន្សំការចំណាយដែលមិនចាំបាច់ និងទ្រព្យសកម្មខូចខាតប្រើប្រាស់មិនបាន។
- **ដំណើរការប្រសើរឡើង៖** តាមរយៈការគ្រប់គ្រងទ្រព្យសកម្មប្រកបដោយប្រសិទ្ធភាព ស្ថាប័នអាចធ្វើឲ្យប្រសើរឡើងនូវការប្រើប្រាស់ទ្រព្យសកម្ម ដែលនាំឲ្យផលិតភាពកាន់តែខ្ពស់ និងភាពជឿជាក់។
- **ពន្យារអាយុកាលនៃទ្រព្យសកម្ម៖** តាមរយៈការគ្រប់គ្រងទ្រព្យសកម្មប្រកបដោយប្រសិទ្ធភាពជួយពន្យាអាយុកាលនៃទ្រព្យសកម្ម និងកាត់បន្ថយចំណាយរបស់ស្ថាប័ន។
- **ចីរភាព៖** តាមរយៈការគ្រប់គ្រងទ្រព្យសកម្មប្រកបដោយចីរភាពជួយដល់ស្ថាប័នកាត់បន្ថយផលប៉ះពាល់បរិស្ថានដោយប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាព និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់។

**អត្ថបទដោយ៖** លោក **ភាន់ សុភាក់**

**ឯកសារយោង៖** ឧត្តមានុវត្តន៍នៃការគ្រប់គ្រងទ្រព្យសកម្មរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.
ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

ស្វែងទាញយកអត្ថបទស្តីពីសវនកម្មផ្សេងទៀត

Facebook Telegram Website